ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់ ការប្រែក្លាយវិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស ទៅជា សាកលវិទ្យាល័យធនធានមនុស្ស

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក. ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និងកីឡា តាមលិខិតលេខ ៣៦៣ អយក.ឧស ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០០៥

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់ការប្រែក្លាយ វិទ្យាស្ថានអភិវឌ្ឍន៍ធនធានមនុស្ស ទៅជាសាកលវិទ្យាល័យធនធានមនុស្ស "Human Resources University" ហៅកាត់ជាភាសាខ្មែរ "ស.ធ.ម." និងហៅកាត់ជាភាសាអង់គ្លេស "HRU" ។ សាកលវិទ្យាល័យនេះ មានទីតាំងស្ថិតនៅអគារលេខ ២ CDE ផ្លូវ ១៦៣ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យធនធានមនុស្ស មានតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវ វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស និងស្ថិតនៅក្រោមឱវាទរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៣ :** សាកលវិទ្យាល័យធនធានមនុស្ស ធ្វើការបណ្តុះបណ្តាលកំរិត :

- បរិញ្ញាប័ត្ររង សិក្សារយៈពេល ២ឆ្នាំ ជាមធ្យម
- បរិញ្ញាប័ត្រ សិក្សារយៈពេល ៤ឆ្នាំ ជាមធ្យម
- ម៉ាស្ទ័រ សិក្សារយៈពេល ២ឆ្នាំ ជាមធ្យម ។

សាកលវិទ្យាល័យនេះត្រូវរៀបចំកម្មវិធីសិក្សាលំអិតដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤ :** សាកលវិទ្យាល័យធនធានមនុស្ស មានមហាវិទ្យាល័យចំនួន ០៥ និងថ្នាក់ក្រោយបរិញ្ញាប័ត្រ :

- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- មហាវិទ្យាល័យសង្គមសាស្ត្រ និងសេដ្ឋកិច្ច
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រនយោបាយ
- ថ្នាក់ក្រោយបរិញ្ញាប័ត្រ ។

ទៅអនាគត សាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យ ឯកទេស ឬ ប្រភេទអប់រំបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៥ :** សាកលវិទ្យាល័យធនធានមនុស្ស មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេច លើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៦ :** តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃសាកលវិទ្យាល័យធនធានមនុស្ស ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាលនៃសាលកវិទ្យាល័យ និងដោយមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧ :** សាកលវិទ្យាល័យធនធានមនុស្ស ត្រូវគោរព និងអនុវត្តតាមការណែនាំ និងបទដ្ឋាន ដែលពាក់ព័ន្ធនឹងការងារបណ្តុះបណ្តាលរបស់ ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់ របស់រាជរដ្ឋាភិបាល សំដៅធានាគុណភាពអប់រំ ។

**មាត្រា ៨ :** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យធនធានមនុស្ស មានភារកិច្ចទទួលខុសត្រូវនៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ធានាអោយបាននូវសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងធ្វើរបាយការណ៍ពីសកម្មភាពសិក្សា ជូននាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់ ។

មាត្រា ៩ : និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យធនធានមនុស្ស និង ទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រ តាមកំរិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាប័ត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យធនធានមនុស្ស ហើយត្រូវបានទទួលស្គាល់ពីក្រសួង អប់រំ យុវជន និងកីឡា ក្នុងករណីសាកលវិទ្យាល័យនេះ បានបំពេញ និង អនុវត្តតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១០ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១១ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និង សាកលវិទ្យាល័យធនធានមនុស្ស ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ